

KHMER

# ការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀន

# Drug-Crime Diversion

ប័ណ្ណពត៌មាន ■ សីហា 2 0 0 2

## ការបំបែកដំណើរកើតមានច្រំដែលនៃគ្រឿងញៀននិងឧក្រិដ្ឋកម្ម

ការប្រើគ្រឿងញៀននិងឧក្រិដ្ឋកម្ម មានចំណងទាក់ទងគ្នាជាខ្លាំង។ អ្នកប្រើគ្រឿងញៀនជាច្រើន ពឹងផ្អែកលើឧក្រិដ្ឋកម្ម ដើម្បីចំណាយទៅលើគ្រឿងញៀន ដែលខ្លួនប្រើ (ឧទាហរណ៍: ចោរកម្មតាមទីលំនៅ)។

ការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀន (Drug-crime diversion) ផ្តល់ឲ្យជនល្មើសទាំងពួងដែលប្រើគ្រឿងញៀន នូវឱកាសដើម្បីទទួលការព្យាបាល និង/ឬ ការអប់រំ ដែលមានគោលបំណងជួយអ្នកទាំងនោះ ឲ្យឈប់ប្រើគ្រឿងញៀន និងការប្រព្រឹត្តឧក្រិដ្ឋកម្មតទៅទៀត។

ដោយផ្តោតទៅលើបទល្មើសគ្រឿងញៀនមិនសូវធ្ងន់ធ្ងរ កម្មវិធីបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀនទាំងឡាយ ក៏មានគោលបំណងផងដែរ ក្នុងការបង្ការកុំឲ្យកើតមាននូវអ្នកប្រើគ្រឿងញៀនប្រព្រឹត្តឧក្រិដ្ឋកម្មទាក់ទងនឹងគ្រឿងញៀន មួយជំនាន់ថ្មីទៀត។

**ការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀន មិនផ្លាស់ប្តូរដល់ស្ថានភាពផ្លូវច្បាប់នៃគ្រឿងញៀនទេ។ កម្មសិទ្ធិ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅតែជាបទល្មើសព្រហ្មទណ្ឌដដែល។**

តាមរយៈការផ្តួចផ្តើមបង្វែរចេញពីគ្រឿងញៀនខុសច្បាប់ (Illicit Drug Diversion Initiative) រដ្ឋាភិបាលសហព័ន្ធកំពុងធ្វើការជាមួយរដ្ឋាភិបាលថ្នាក់រដ្ឋនិងដែនដីទាំងអស់ ដើម្បីបង្កើតរបៀបដោះស្រាយស្របគ្នាមួយនៅទូទាំងប្រទេស សំរាប់ការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀន។

### តើការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀនជួយសហគមន៍យ៉ាងណា?

- ការតភ្ជាប់កម្មវិធីអប់រំនិងព្យាបាលគ្រឿងញៀន ទៅនឹងប្រព័ន្ធយុត្តិធម៌ ផ្តល់គ្រឿងលើកទឹកចិត្តមាំមួន ឲ្យស្ថិតនៅក្នុងការព្យាបាល
- ការផ្តល់ការព្យាបាលលើបញ្ហាគ្រឿងញៀន ជួយការពារកុំឲ្យមានឧកិដ្ឋកម្ម
- កម្មវិធីទាំងពួង ជំរុញទឹកចិត្តអ្នកចូលរួមឲ្យប្រកាន់ការទទួលខុសត្រូវចំពោះការប្រើគ្រឿងញៀននិងឧក្រិដ្ឋកម្ម ទាក់ទងនឹងគ្រឿងញៀនរបស់ខ្លួន
- ចំនួនអ្នកឡើងតុលាការដោយសារតែបទចោទគ្រឿងញៀនតូចតាចមានកាន់តែតិចទៅ។

## តើគេកំពុងធ្វើអ្វីនៅអំពី ការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀន នៅក្នុងរដ្ឋ NSW ?

ការបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀនដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងរដ្ឋ NSW មានកម្មវិធីប្រាំ។ កម្មវិធីខ្លះ អនុវត្តនៅពាសពេញរដ្ឋ ហើយកម្មវិធីខ្លះទៀត កំពុងសាកល្បងអនុវត្តនៅក្នុងតំបន់ជាក់លាក់។ កម្មវិធីទាំងនេះកំពុងត្រូវបានកែប្រែដើម្បីឲ្យសក្តិសមនឹងសេចក្តីត្រូវការរបស់សហគមន៍មូលដ្ឋាននិងតំបន់ទាំងឡាយ។

កម្មវិធីនីមួយៗ ផ្តោតទៅលើជនល្មើសនៅតាមដំណាក់កាលផ្សេងគ្នានៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ អន្តរាគមន៍ទាន់ពេល គឺជាការយកចិត្តទុកដាក់ទៅលើជនល្មើសតូចតាច ដែលជាប់ពាក់ព័ន្ធតិចតួចទៅនឹងឧក្រិដ្ឋកម្ម ចំណែកឯជនល្មើសដែលមានបញ្ហាគ្រឿងញៀនធ្ងន់ធ្ងរ ត្រូវឈានចូលទៅក្នុងកម្មវិធីដែលមើលខុសត្រូវជាខ្លាំង។

អ្នកចូលរួមនៅក្នុងកម្មវិធីទាំងនេះ ត្រូវបំពេញទៅតាមតម្រូវការនៃកម្មវិធីដែលអាចមានរួមទាំងការតាមពិនិត្យ និង បទបញ្ញត្តិយ៉ាងតឹងរ៉ឹង។

កម្មវិធីបង្វែរចេញពីឧក្រិដ្ឋកម្មគ្រឿងញៀនទាំងអស់ ត្រូវបានតាមពិនិត្យនិងវាយតម្លៃ។ នៅពេលដែលមានភស្តុតាងបង្ហាញថា វិធីដោះស្រាយណាមួយមានប្រសិទ្ធភាពហើយនោះ វិធីនេះនឹងត្រូវគិតគូរសំរាប់ការប្រើប្រាស់តទៅទៀត នៅក្នុងរដ្ឋ NSW ។ បើវិធីណាមួយគ្មានប្រសិទ្ធភាពទេនោះ វិធីនេះនឹងត្រូវបញ្ឈប់លែងប្រើតទៅទៀត។

## 1. ការផ្លាស់ប្តូរច្បាប់ជនល្មើសវ័យក្មេង* (Young Offenders Act*)

នៅខែមេសា ឆ្នាំ 2002 ច្បាប់ជនល្មើសវ័យក្មេង បានត្រូវកែប្រែដើម្បីរួមបញ្ចូលទាំងបទល្មើសគ្រឿងញៀនតូចតាច (ដូចជាកម្មសិទ្ធិគ្រឿងញៀនតាមបរិមាណតិចតួចជាដើម) ដែលប្រព្រឹត្តដោយបណ្តាជនវ័យក្មេង។

ការផ្លាស់ប្តូរនេះអនុញ្ញាតឲ្យជនល្មើសគ្រឿងញៀនតូចតាចទទួលជំនួយ និងមានគោលបំណងដើម្បីបញ្ឈប់អ្នកទាំងនោះកុំឲ្យប្រព្រឹត្តល្មើសសាជាថ្មីទៀត។ ការកែប្រែនេះអនុវត្តនៅក្នុងគ្រប់កន្លែងទាំងអស់នៅក្នុងរដ្ឋ NSW ។

កម្មសិទ្ធិគ្រឿងញៀន នៅតែជាអំពើខុសច្បាប់។ ច្បាប់ជនល្មើសវ័យក្មេង គ្រាន់តែផ្តល់ជំរើសផ្សេងក្រៅពីការត្រូវឡើងទៅតុលាការ នៅក្នុងករណីខ្លះតែប៉ុណ្ណោះ។ នៅរាល់ករណីទាំងអស់ ប៉ូលិសនៅតែមានសេរីភាពក្នុងការសំរេចលើការប្តឹងចោទជនល្មើស។

ច្បាប់ជនល្មើសវ័យក្មេង មិនដោះស្រាយបញ្ហាបណ្តាជនវ័យក្មេងដែលគេសង្ស័យថាជាអ្នកផ្តល់ឬជួញដូរគ្រឿងញៀនឡើយ។ ប៉ូលិសនឹងប្តឹងចោទជនល្មើសទាំងនេះឲ្យឡើងតុលាការ។ ប៉ូលិសធ្វើតាមគោលការណ៍ណែនាំផ្លូវច្បាប់យ៉ាងតឹងរ៉ឹង ក្នុងការសំរេចនូវពេលវេលានិងរបៀបអនុវត្តច្បាប់នេះ។

### តើវិធីណានៅសំរាប់ដោះស្រាយនឹងជនល្មើសវ័យក្មេង នៅក្រោមច្បាប់នេះ?

ច្បាប់នេះអនុវត្តចំពោះបណ្តាជនវ័យក្មេងដែលឃាត់ខ្លួនដោយប៉ូលិសដោយសារបទល្មើសផ្សេងៗយ៉ាង ទូលំទូលាយ ដោយមានរួមទាំង :

- កម្មសិទ្ធិគ្រឿងញៀនខុសច្បាប់តាមបរិមាណតិចតួច
- កម្មសិទ្ធិសំភារៈសំរាប់ប្រើគ្រឿងញៀន ឬ
- ការប្រព្រឹត្តបទល្មើសគ្រឿងញៀនតូចតាចឯទៀត[០]។

ជនល្មើសវ័យក្មេងអាចទទួល*ការរំលឹកឲ្យប្រុងប្រយ័ត្ន (warning)* *ការព្រមាន (caution)* ឬអាចត្រូវបានបញ្ជូនទៅកាន់*ការប្រជុំវិនិច្ឆ័យយុវជន (youth justice conference)* ។

ប៉ូលិសអាចផ្តល់ *ការរំលឹកឲ្យប្រុងប្រយ័ត្ន* សំរាប់បទល្មើសអហិង្សាមិនសូវធ្ងន់ធ្ងរ។ ប៉ូលិសផ្តល់ការរំលឹកឲ្យប្រុងប្រយ័ត្ននៅតាមដងផ្លូវ ហើយជនវ័យក្មេងនេះមិនចាំបាច់សារភាពថាបានធ្វើបទល្មើសឡើយ។ ប៉ូលិសកត់ត្រាពត៌មានអំពីជនវ័យក្មេងនោះ និងបទល្មើសរបស់គេ។

*ការព្រមាន* គឺជាទំរង់ការផ្លូវការមួយ នៅពេលដែលជនវ័យក្មេងត្រូវបានចាប់ខ្លួន ហើយសារភាពថាបានធ្វើខុស។ នៅពេលទទួលការព្រមាន ជនវ័យក្មេងនោះមានម្តាយឬឪពុក / អាណាព្យាបាល នៅអមជាមួយនឹងខ្លួន ហើយប្រហែលជាមានបុគ្គលិកគ្រឿងញៀននិងសុរា នៅអមជាមួយផងដែរ។ ជនវ័យក្មេងនេះចុះហត្ថលេខាលើលិខិតព្រមានផ្លូវការ។ ជនវ័យក្មេងនេះទទួលពត៌មានអំពីផលវិបាកផ្នែកច្បាប់និងសុខភាពនៃការប្រើគ្រឿងញៀន និងពត៌មានអំពីសេវាកម្មព្យាបាលនិងពិគ្រោះផ្តល់ឱវាទ។

បើកាលៈទេសៈទាំងឡាយមានភាពកាន់តែធ្ងន់ធ្ងរឡើង នោះគេអាចរៀបចំឲ្យមានការប្រជុំវិនិច្ឆ័យយុវជនមួយ។ ប៉ូលិស និង/ឬ តុលាការ អាចបញ្ជូនជនល្មើសទៅកាន់ការប្រជុំវិនិច្ឆ័យយុវជនមួយ។ ការប្រជុំនេះ ត្រូវបានរៀបចំសំរួលដោយអ្នកកោះហៅម្នាក់ ដែលហ្វឹកហ្វឺនដោយក្រសួងយុត្តិធម៌យុវជន (Department of Juvenile Justice)។

ជនល្មើសវ័យក្មេងចូលរួមក្នុងអង្គប្រជុំនេះព្រមជាមួយនឹងជនទាំងឡាយដែលបានរងផលប៉ះពាល់មិនល្អជាខ្លាំង ដោយសារតែអំពើល្មើស ឬ សកម្មភាពរបស់ជនល្មើស។ អ្នកគាំទ្រទាំងឡាយអមដំណើរភាគីនីមួយៗ។ ជនវ័យក្មេងនេះត្រូវពន្យល់សកម្មភាពរបស់ខ្លួន ហើយទទួលខុសត្រូវចំពោះបទល្មើសរបស់ខ្លួន។ ជនវ័យក្មេងនេះនិងជនរងគ្រោះ យល់ស្របទៅនឹងផែនការមានលទ្ធផលសមរម្យមួយ ដែលជនវ័យក្មេងនេះត្រូវតែបំពេញ។ ផែនការនេះ ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាគ្រឿងញៀននិងបញ្ហាឯទៀត ដែលបានរួមចំណែកចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ជនវ័យក្មេងនោះ។ ផែនការនេះអាចមានរួមទាំងការព្យាបាលនិងការពិគ្រោះផ្តល់ឱវាទ។ ការរីកចំរើនត្រូវបានតាមពិនិត្យមើល។

គេនឹងមិនចាត់ឲ្យមានវិធានការតទៅទៀតឡើយ បើជនល្មើសបំពេញសព្វគ្រប់ទៅតាមផែនការនេះ។ បើពុំនោះសោតទេ ករណីនេះនឹងត្រូវប្រគល់ទៅឲ្យប៉ូលិស ឬ តុលាការវិញ។

*ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង Department of Juvenile Justice ទូរស័ព្ទ: (02) 9289 3319 ។*

[Ø] តុលាការមូលដ្ឋាន អាចស្តាប់ក្តីនៃបទល្មើសតូចតាច។

*Nicky ជាក្មេងស្រីអាយុ 15 ឆ្នាំ បានត្រូវចាប់ខ្លួនដោយសារការលួចឥវ៉ាន់និងកម្មសិទ្ធិហេរ៉ូអ៊ីនតិចតួច។ ប៉ូលិសបានសំភាសន៍ Nicky ហើយដោយសារតែអាយុរបស់នាង គេបានអញ្ជើញភ្នាក់ងារទំនាក់ទំនងយុវជននិងប៉ូលិស (Police Youth Liaison Officer – YLO) ឲ្យចូលរួមដើម្បីផ្តល់ជំនួយ។ ក្នុងអម្លុងការសំភាសន៍នោះ គេបានដឹងច្បាស់ថា ឥវ៉ាន់ដែលលួចនេះ គឺដើម្បីលក់យកប្រាក់ទៅទិញគ្រឿងញៀន។ ក្រោយពីការសំភាសន៍នេះមក ភ្នាក់ងារ YLO បាននិយាយជាមួយ Nicky និងម្តាយរបស់នាង អំពីលទ្ធភាពនៃជំរើសទាំងពួងដើម្បីព្យាបាលបញ្ហាគ្រឿងញៀន។*

*ក្រោយពីពិចារណាថាតើត្រូវដោះស្រាយនឹង Nicky នៅក្រោមច្បាប់ជនល្មើសវ័យក្មេងដែរឬទេនោះ ភ្នាក់ងារ YLO បានសំរេចថា នាងមានសិទ្ធិទទួលការព្រមានចំពោះបទល្មើសទាំងនេះ។ ដោយសារតែអំពើនេះគឺជាបទល្មើសតូចតាចនិងជាលើកដំបូង ប៉ូលិសបានសំរេចចេញការព្រមាន។ ភ្នាក់ងារ YLO បានរក្សាការទាក់ទងជាមួយនឹងគ្រួសាររបស់ Nicky ក្នុងអម្លុងពេលរវាងការសំភាសន៍ និងការផ្តល់ការព្រមានដោយប៉ូលិស។ Nicky បានប្រើគ្រឿងញៀនតទៅទៀតក្នុងអម្លុងពេលនោះ។*

*នៅពេលធ្វើការព្រមាននេះ Nicky បានយល់ស្របថា ការព្យាបាលគ្រឿងញៀននឹងផ្តល់ប្រយោជន៍ប្រសើរបំផុតទៅឲ្យនាង។ ភ្នាក់ងារ YLO បានទាក់ទងកម្មវិធីស្នាក់នៅសំរាប់ជនជំទង់ ហើយ Nicky បានចូលរួមនៅក្នុងកម្មវិធីនោះ។*

*របាយការណ៍ទាំងអស់ចង្អុលបង្ហាញថា ការព្យាបាលកំពុងតែប្រព្រឹត្តទៅយ៉ាងប្រសើរ។ គេសង្ឃឹមថា ពេលព្យាបាលនេះនឹងជួយ Nicky ក្នុងការគ្រប់គ្រងការរស់នៅរបស់នាង ដោយកុំឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី ឬ ប្រើគ្រឿងញៀនខុសច្បាប់ឡើយ។*

## 2. គំរោងផ្តល់ការព្រមានដល់មនុស្សពេញវ័យពាក់ព័ន្ធនឹងពពួកកញ្ឆាកាណាប៊ីស* (Adult Cannabis Cautioning Scheme*)

គំរោងផ្តល់ការព្រមានដល់មនុស្សពេញវ័យពាក់ព័ន្ធនឹងកាណាប៊ីស ដែលបង្កើតឲ្យមានឡើងដោយរដ្ឋាភិបាល NSW ដើម្បីជាការសាកល្បងពេលមួយឆ្នាំ នៅក្នុងខែមេសា ឆ្នាំ 2000 បានត្រូវបន្ថែមពេលចំនួនពីរឆ្នាំទៀត។ ការផ្តួចផ្តើមទូទាំងរដ្ឋនេះ ផ្តល់ឲ្យប៉ូលិសនូវសេរីភាពក្នុងការសំរេចធ្វើការព្រមាន ជាជាងការប្តឹងចោទចំពោះជនល្មើសពាក់ព័ន្ធនឹងកាណាប៊ីសតិចតួច។

**គំរោងនេះមិនប្រកាន់រើសអើង ឬធ្វើឲ្យកាណាប៊ីសទៅជាស្របច្បាប់ទេ។ នៅក្នុងរដ្ឋ NSW ការប្រើ កម្មសិទ្ធិ ការដាំ ការនាំចូល និងការលក់កាណាប៊ីស នៅតែជាអំពើខុសច្បាប់។**

ប៉ូលិសអាចចេញលិខិតព្រមាន ទៅឲ្យជនពេញវ័យទាំងឡាយដែលប៉ូលិសចាប់បានដោយមានស្លឹកកាណាប៊ីសតិចតួច (មិនច្រើនជាង 15 ក្រាម) និង/ឬ ចំពោះសំភារៈសំរាប់ប្រើកាណាប៊ីស។ លិខិតព្រមាននេះ ផ្តល់ពត៌មានសុខភាពនិងផ្លូវច្បាប់លើការប្រើកាណាប៊ីស ហើយផ្តល់លេខទូរស័ព្ទទាក់ទងសេវាកម្ម ពត៌មានគ្រឿងញៀននិងសុរា (Alcohol and Drug Information Service – ADIS) ។ សេវាកម្ម ADIS (ធ្វើការគ្រប់ពេលម៉ោង ដែលមានទូរស័ព្ទចាប់ផ្តើមដោយលេខ 1800) បានត្រូវពង្រីកឡើងដើម្បីផ្តល់ឲ្យជនល្មើសដែលទទួលការព្រមាន នូវពត៌មានអំពីសេវាកម្មព្យាបាល ពិគ្រោះផ្តល់ឱវាទ និងជំនួយ។ គំរោងនេះមានន័យថា ជនល្មើសពាក់ព័ន្ធនឹងកាណាប៊ីសតិចតួច ចៀសវាងការទទួលទោសព្រហ្មទណ្ឌ។

ជនល្មើសនីមួយៗអាចទទួលការព្រមានតែពីរលើកប៉ុណ្ណោះ។ ជនល្មើសណាមួយដែលទទួលការព្រមានលើកទីពីរ នឹងត្រូវចូលរួមការពិគ្រោះផ្តល់ឱវាទនិងអប់រំជាដាច់ខាត។

បើជនល្មើសប្រើកាណាប៊ីសតទៅទៀត ហើយត្រូវបានប៉ូលិសចាប់ខ្លួន ជននោះនឹងត្រូវប៉ូលិសចោទប្តឹង ហើយត្រូវឡើងតុលាការ។

អ្នកដែលមានប្រវត្តិអំពីអំពើល្មើសហិង្សា ផ្លូវភេទ ឬគ្រឿងញៀន មិនអាចទទួលការព្រមានឡើយ។

*ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង NSW Police Service ទូរស័ព្ទលេខ: (02) 9265 5185 ។*

## 3. ការបញ្ជូនទាន់ពេលដោយចៅក្រមឲ្យទៅទទួលការព្យា បាល* (Magistrate Early Referral into Treatment - MERIT*)

កម្មវិធី MERIT នេះ ត្រូវបានរៀបចំឡើងសំរាប់ជនចុងចោទដែលមានសិទ្ធិទទួលការធានាឲ្យនៅក្រៅឃុំ ហើយដែលបង្ហាញលទ្ធភាពទទួលការព្យាបាលនិងកែឲ្យបានល្អឡើងវិញ។ កម្មវិធី MERIT មានគោលបំណងបង្ការ កុំឲ្យជនចុងចោទប្រព្រឹត្តឧក្រិដ្ឋកម្ម និងវិលទៅប្រើគ្រឿងញៀនវិញ ដោយធ្វើឲ្យការចូលរួមក្នុងការព្យាបាលគ្រឿងញៀន គឺជាលក្ខខណ្ឌមួយនៃការធានាឲ្យនៅក្រៅឃុំ។

កម្មវិធីនេះបានពិសោធន៍ដោយជោគជ័យនៅក្នុង Lismore ហើយនឹងបង្កើតនៅក្នុងភូមិភាគសេវាកម្មសុខភាពតំបន់ទាំងអស់ក្នុងរដ្ឋ NSW ក្នុងអម្លុងពេលពីរឆ្នាំខាងមុខនេះ។

នៅក្រោមកម្មវិធី MERIT ចៅក្រមបញ្ជូនជនចុងចោទទៅកាន់កម្មវិធីខិតខំព្យាបាលនិងកែលំអឲ្យបានល្អឡើងវិញ ជាផ្នែកនៃលក្ខខណ្ឌទាំងឡាយសំរាប់ការធានាឲ្យជននោះនៅក្រៅឃុំ។ កម្មវិធី MERIT គឺជាការស្ម័គ្រចិត្ត ហើយការរីកចំរើនលើការព្យាបាលរបស់ជនចុងចោទ អាចទទួលការពិចារណាក្នុងអម្លុងការស្តាប់ក្តីនិងការកាត់ទោសចុងក្រោយ។

អ្នកវិជ្ជាជីវៈសុខុមាលភាពនិងសុខភាពមានការហ្វឹកហ្វឺនពិសេសទាំងឡាយគ្រប់គ្រងអ្នកចូលរួមទាំងពួងទៅតាម ករណីនីមួយៗយ៉ាងដិតដល់ នៅពាសពេញអម្លុងពេលធានាឲ្យនៅក្រៅឃុំរបស់គេ ។ ចៅក្រមទទួលរបាយការណ៍ជាប្រក្រតីអំពីការរីកចំរើនរបស់អ្នកទាំងនោះ រហូតទាល់តែបញ្ចប់

ការស្តាប់ក្តីនៅតុលាការ នៅដំណាច់ពេលធានាឲ្យនៅក្រៅឃុំ ដែលធម្មតាមានរយៈពេលបីខែ។

ជនចុងចោទទាំងឡាយដែលជាប់ចោទពីបទល្មើសហិង្សាឬផ្លូវភេទ គ្មានសិទ្ធិទទួលកម្មវិធីនេះទេ។

### តើកម្មវិធី MERIT ធ្វើការតាមរបៀបយ៉ាងណា ?

កម្មវិធីព្យាបាលគ្រឿងញៀនមួយ ត្រូវបានរៀបចំឡើងសំរាប់អ្នកចូលរួម។ បុគ្គលិកសុខាភិបាលមើលខុសត្រូវករណីមួយរូប ផ្តល់ជំនួយនិងការណែនាំតាមរយៈការព្យាបាលនេះ។ កម្មវិធីនេះអាចមានរួមទាំង :

- ការបន្សាបជាតិពុលគ្រឿងញៀន
- ការព្យាបាលដោយថ្នាំមេថាដូន ឬ ការព្យាបាលដោយប្រើឱសថឯទៀត (ការព្យាបាលរោគសំរាប់អ្នកពឹងអាស្រ័យលើគ្រឿងញៀន)
- កម្មវិធីស្នាក់នៅ និងកែឲ្យល្អឡើងវិញផ្សេងទៀត
- ការពិគ្រោះផ្តល់ឱវាទសំរាប់បុគ្គល ឬ ក្រុម
- កម្មវិធីបង្ការកុំឲ្យលាប់ឡើងវិញ ដើម្បីបង្ការកុំឲ្យជនចុងចោទប្រើគ្រឿងញៀនសាជាថ្មី។

បើជនចុងចោទមិនចូលរួមការព្យាបាល ប្រព្រឹត្តបទល្មើសតទៅទៀត ឬមិនអនុវត្តតាមលក្ខខណ្ឌធានាឲ្យនៅក្រៅឃុំ គេនឹងជំរាបចៅក្រម ហើយអាចបញ្ឈប់កម្មវិធីនេះ។ នៅពេលដែលបំពេញកម្មវិធីនេះហើយ ចៅក្រមអាចពិចារណាក៏រិតរីកចំរើនរបស់ជនចុងចោទ នៅពេលកាត់ទោសចុងក្រោយ។

*ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង NSW Attorney General's Department ។ ទូរស័ព្ទលេខ: (02) 9228 7620 ។*

*Peter មានអាយុ 25 ឆ្នាំ ហើយបាននិងកំពុងប្រើហេរ៉ូអ៊ីនអស់ពេល 9 ឆ្នាំ។ Peter បានត្រូវជាប់ចោទពីបទល្មើស លួចគាស់និងចូលទៅលួចឥវ៉ាន់ ដែលពាក់ព័ន្ធនឹងការប្រើគ្រឿងញៀនរបស់ខ្លួន។ នេះជាលើកដំបូងហើយដែល Peter បានឡើងតុលាការ។*

*ដោយសារតែប្រវត្តិប្រើគ្រឿងញៀនរបស់ខ្លួន Peter បានត្រូវបញ្ជូនឲ្យទៅធ្វើការពិនិត្យវាយតម្លៃសំរាប់កម្មវិធី MERIT ។ អ្នកវិជ្ជាជីវៈសុខភាពមួយរូបបានពិនិត្យវាយតម្លៃបញ្ហាគ្រឿងញៀនរបស់ Peter ។ Peter បានយល់ព្រមចូលរួមនៅក្នុងកម្មវិធីមេថាដូន ចូលរួមក្រុមអប់រំ MERIT ហើយទៅជួបបុគ្គលិកគ្រប់គ្រងករណីរបស់ខ្លួន ដើម្បីទទួលការពិគ្រោះផ្តល់ឱវាទជាទៀងទាត់។ ការស្តាប់ក្តីនៅតុលាការ បានត្រូវពន្យារពេល នៅក្នុងពេលដែល Peter ចូលរួមនៅក្នុងកម្មវិធី MERIT ។ ចៅក្រមបានទទួលរបាយការណ៍ជាប្រក្រតី អំពីការអនុវត្តតាមកម្មវិធី MERIT របស់ Peter ។*

*Peter បានបំពេញកម្មវិធី MERIT ដោយជោគជ័យ រយៈពេល 15 អាទិត្យ។*

*ដំណើរការនៅតុលាការរបស់ Peter នឹងបញ្ចប់នៅពេលឆាប់ៗនេះ។ Peter បានសំរេចឆ្លើយថាមានទោស។ របាយការណ៍មួយស្តីអំពីការរីកចំរើនរបស់ Peter តាមរយៈកម្មវិធី MERIT នឹងដាក់ជូនចៅក្រមសំរាប់ការពិចារណា។*

*គ្រាសព្វថ្ងៃនេះ Peter ធ្វើការជាប់លាប់ ហើយកំពុងស្ថិតនៅក្នុងកម្មវិធីមេថាដូន។*

## 4. តុលាការគ្រឿងញៀនជនពេញវ័យ (Adult Drug Court)

តុលាការគ្រឿងញៀនជនពេញវ័យលើកដំបូងក្នុងប្រទេសអូស្ត្រាលី បានធ្វើប្រតិបត្តិការនៅ Parramatta កាលពីខែកុម្ភៈ ឆ្នាំ 1999 ។ តុលាការគ្រឿងញៀននេះ មានគោលបំណងជួយជនល្មើសពេញវ័យ ដែលមានបញ្ហាគ្រឿងញៀនធ្ងន់ធ្ងរ បំបែកដំណើរកើតមានច្រំដែលនៃគ្រឿងញៀននិងឧក្រិដ្ឋកម្ម ដោយផ្តល់កម្មវិធីព្យាបាលនិងកែឲ្យបានល្អឡើងវិញមួយដែលមានការមើលខុសត្រូវ។

តុលាការមូលដ្ឋានអាចបញ្ជូនជនចុងចោទទាំងពួងមកពី Western Sydney ទៅកាន់តុលាការគ្រឿងញៀន NSW ។ ការបញ្ជូនទៅកាន់តុលាការនេះ មានលទ្ធភាពធ្វើទៅបាន បើអ្នកទាំងនោះ :

- ចូលរួមនៅក្នុងដំណើរការបន្សាបជាតិពុលគ្រឿងញៀន
- មានលទ្ធភាពសំរាប់កែឲ្យបានល្អឡើងវិញ ហើយ
- គ្មានជាប់ចោទពីបទល្មើសហិង្សាឬផ្លូវភេទ ឬបទល្មើសគ្រឿងញៀនដែលអាចប្តឹងចោទទាំងស្រុងដោយតុលាការនោះឡើយ[†]។

### តើតុលាការគ្រឿងញៀន NSW ធ្វើការតាមរបៀបណាដែរ ?

ក្រុមរបស់តុលាការគ្រឿងញៀនបង្កើតកម្មវិធីដោយឡែកសំរាប់អ្នកចូលរួមនីមួយៗ ដែលមានរយៈពេល 12 ខែឬច្រើនជាងនេះ។ កម្មវិធីនេះជាប់ពាក់ព័ន្ធជាប្រក្រតីនឹង :

- ពេលព្យាបាលគ្រឿងញៀននិងកែឲ្យបានល្អឡើងវិញ
- ពេលពិគ្រោះផ្តល់ឱវាទ
- ការអប់រំ និងការហ្វឹកហ្វឺនការងារ
- ការពិនិត្យពិច័យរកមើលគ្រឿងញៀន
- ការរាយការណ៍ជូនតុលាការវិញ។

ប្រធានករណីម្នាក់ តាមពិនិត្យអ្នកចូលរួមនីមួយៗ។ ចៅក្រមនិងក្រុមតុលាការគ្រឿងញៀន តាមពិនិត្យការរីកចំរើនរបស់បុគ្គលនីមួយៗ ហើយអាចផ្លាស់ប្តូរឬបញ្ឈប់កម្មវិធីនេះ បើចាំបាច់។

នៅដំណាច់កម្មវិធីនេះ ជនល្មើសទទួលការកាត់ទោសចុងក្រោយពីតុលាការគ្រឿងញៀន ។ ការកាត់ទោសនេះ យកមកគិតគូរនូវការកាត់ទោសដើមដំបូង និងការរីកចំរើនរបស់ជនល្មើស នៅក្នុងកម្មវិធីរបស់តុលាការគ្រឿងញៀន ។

*ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង NSW Attorney General's Department ។ ទូរស័ព្ទលេខ: (02) 9228 7620 ។*

[†]តុលាការមូលដ្ឋានមិនអាចស្តាប់ក្តីនៃបទល្មើសគ្រឿងញៀនដែលអាចប្តឹងចោទទេ។

*Andrea មានអាយុ 39 ឆ្នាំ នៅពេលដែលគាត់ឡើងតុលាការគ្រឿងញៀនជាលើកដំបូង។ គាត់គ្មានដៃគូរស់នៅជាមួយទេ ហើយមានកូនបីនាក់ ដែលបានរស់នៅក្រោមការថែទាំនៃជីដូនរបស់គេ នៅក្នុងពេលភាគច្រើន។*

*Andrea បានឈប់រៀននៅសាលាមធ្យមសិក្សា កាលពីអាយុ 15 ឆ្នាំ ហើយបានធ្វើការមិនទៀងទាត់ នៅតាមហាងលក់ទំនិញចំរុះ និង ហាងលក់សាំង។*

*Andrea មានប្រវត្តិប្រព្រឹត្តឧក្រិដ្ឋកម្មអស់ពេលយូរមកហើយ ហើយបានជាប់ឃុំនៅក្នុងមណ្ឌលឃុំឃាំងយុវជន និងពន្ធនាគារជនពេញវ័យ។ បទល្មើសរបស់គាត់មានលក្ខណៈខុសៗគ្នា ប៉ុន្តែបទល្មើសទាំងអស់នោះ គឺពាក់ព័ន្ធនឹងការពឹងផ្អែកលើហេរ៉ូអ៊ីនរបស់គាត់។*

*Andrea បានចាប់ផ្តើមប្រើគ្រឿងញៀននៅពេលមានអាយុ 13 ឆ្នាំ ហើយមានការពឹងផ្អែកជាខ្លាំងទៅលើហេរ៉ូអ៊ីន តាំងពីពេលដែលគាត់មានអាយុ 16 ឆ្នាំមកម៉្លេះ។ គាត់បានសាកល្បងទទួលការព្យាបាលមេថាដូន ប៉ុន្តែបែបបទរស់នៅដ៏ច្របូកច្របល់របស់គាត់ (គ្មានការងារ ឬទីលំនៅជាប់លាប់) បានធ្វើឲ្យគាត់លំបាកនឹងអនុវត្តតាមកម្មវិធីមួយ។ Andrea បាននិយាយថា គាត់មានមិត្តភក្តិដែលជាអ្នកប្រើគ្រឿងញៀន ហើយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មតែប៉ុណ្ណោះ។*

*Andrea បានឡើងតុលាការ លើបទចោទកម្មសិទ្ធិគ្រឿងញៀន។ តុលាការបានកាត់ទោសឲ្យគាត់ជាប់ពន្ធនាគារ តាមកាលកំណត់ចំនួនបីខែនិងមួយអាទិត្យ។ ការកាត់ទោសនេះបានត្រូវផ្អាកសិន ដោយរង់ចាំការដាក់បញ្ចូលទៅក្នុងកម្មវិធីរបស់តុលាការគ្រឿងញៀន។*

*នៅក្នុងពេលស្ថិតនៅក្នុងកម្មវិធីរបស់តុលាការគ្រឿងញៀន គាត់បានរស់នៅជាមួយនឹងគ្រួសាររបស់គាត់ ដោយមានរួមទាំងកូនបីនាក់របស់គាត់ផងដែរ។ ម្តាយរបស់គាត់បានជួយគាត់ជាខ្លាំង។*

*Andrea មានបញ្ហាខ្លះនៅពេលដើមដំបូង ដើម្បីសំរបសំរួលខ្លួនចូលទៅក្នុងទំរង់ការរស់នៅជាប្រចាំរបស់គ្រួសារគាត់ ប៉ុន្តែអាចដោះស្រាយបញ្ហាទាំងនេះនៅក្នុងពេលពិគ្រោះផ្តល់ឱវាទ។ គាត់បានបញ្ចប់វគ្គសិក្សារយៈពេល 18 អាទិត្យ នៅ TAFE ហើយបានកាត់ផ្តាច់ចំណងទាក់ទងជាមួយនឹងមិត្តភក្តិចាស់របស់គាត់។*

*Andrea បានបំពេញកម្មវិធីតុលាការគ្រឿងញៀនរបស់គាត់ដោយជោគជ័យ។ ចាប់តាំងពីចេញពីកម្មវិធីនេះមក គាត់បានរក្សាការទាក់ទងជាមួយនឹងប្រធានមើលខុសត្រូវករណី និងអ្នកពិគ្រោះផ្តល់ឱវាទរបស់គាត់ ហើយនៅតែមិនបានប្រើគ្រឿងញៀនឡើយ។*

## 5. តុលាការគ្រឿងញៀនយុវជន* (Youth Drug Court*)

ការសាកល្បងរយៈពេលពីរឆ្នាំនៃតុលាការគ្រឿងញៀនយុវជន បានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ 2000 នៅក្នុង Western Sydney ។ ជនល្មើសវ័យក្មេងទាំងឡាយនៅឯតុលាការកុមារ អាចត្រូវបានបញ្ជូនទៅកាន់តុលាការគ្រឿងញៀនយុវជន បើជនទាំងនោះ :

- មានបញ្ហាគ្រឿងញៀនឬសុរា យ៉ាងធ្ងន់ធ្ងរ
- ឆ្លើយថាមានទោស
- រស់នៅក្នុង Western Sydney
- មិនអាចទទួលការដោះស្រាយនៅក្រោមច្បាប់ជនល្មើស វ័យក្មេងបាន
- សក្តិសមទទួលការព្យាបាលនិងការធ្វើឲ្យបានល្អឡើងវិញ ហើយ
- យល់ព្រមចូលទៅក្នុងកម្មវិធីព្យាបាលមួយ នៅក្នុងពេលស្ថិតនៅក្នុងការធានាឲ្យនៅក្រៅឃុំ។

### តើតុលាការគ្រឿងញៀនយុវជន ធ្វើការតាមរបៀបណា ?

ជនវ័យក្មេងនឹងទទួលនូវផែនការកម្មវិធីផ្ទាល់ខ្លួនមួយ ដែលជននេះត្រូវតែធ្វើតាម។ ផែនការនេះមានរយៈពេលប្រាំមួយខែឬយូរជាងនេះ ហើយមានរួមទាំងគំរោងព្យាបាលទាំងពួង ការណាត់ជួបប្រក្រតីជាមួយនឹងតុលាការ និងជំនួយទៅតាមសេចក្តីត្រូវការសុខភាព ទីលំនៅនិងអប់រំ។ បុគ្គលិកជំនួយម្នាក់ ជួយអ្នកចូលរួមទាំងឡាយដើម្បីអនុវត្តតាមផែនការកម្មវិធីនេះ។ គ្រួសារក៏ត្រូវបានជំរុញទឹកចិត្តឲ្យមានតួនាទីមួយនៅក្នុងកម្មវិធីព្យាបាលនេះផងដែរ។

គេអាចបញ្ឈប់ផែនការកម្មវិធីនេះ បើជនវ័យក្មេងនោះប្រើគ្រឿងញៀននិងសុរាតទៅទៀត ឬប្រព្រឹត្តបទល្មើសផ្សេងទៀត។ បើជនវ័យក្មេងនេះមិនបំពេញកម្មវិធីនេះទេ គេត្រូវវិលទៅកាន់តុលាការវិញ ដើម្បីប្រឈមមុខនឹងបទចោទកាលពីដើមដំបូងទាំងឡាយ។

នៅពេលបំពេញផែនការកម្មវិធីនេះហើយ ការចូលរួមនិងការរីកចំរើនរបស់ជនល្មើសវ័យក្មេងនេះ ត្រូវបានពិចារណានៅពេលកាត់ទោសចុងក្រោយ។

*ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង NSW Attorney General's Department ។ ទូរស័ព្ទលេខ: (02) 9228 7620 ។*

*Max ដែលមានអាយុ 17 ឆ្នាំ មានបញ្ហាជាច្រើននៅក្នុងជីវិតរបស់គេ នៅពេលបានត្រូវបញ្ជូនខ្លួនទៅកាន់តុលាការគ្រឿងញៀនយុវជន។ យុវជននេះជក់ហេរ៉ូអ៊ីនគិតជាប្រាក់ប្រហែល $50 ក្នុងមួយថ្ងៃៗ ប្រព្រឹត្តបទល្មើសដើម្បីរកប្រាក់សំរាប់ទ្រទ្រង់ការប្រើគ្រឿងញៀនរបស់ខ្លួន មិនបានទាក់ទងជាមួយគ្រួសារអស់ពេលជាងប្រាំឆ្នាំមកហើយ ហើយគ្មានទីលំនៅជាប់លាប់ទេ។*

*ក្រោយពីការពិនិត្យវាយតម្លៃបញ្ហាគ្រឿងញៀនរបស់ Max មក គេបានបង្កើតផែនការគ្រប់គ្រងករណីផ្ទាល់ខ្លួនមួយ ដែលតំរូវឲ្យយុវជននេះចូលរួមការប្រជុំពិគ្រោះទទួលឱវាទទៀងទាត់ និងស្វែងរកទីលំនៅជាប់លាប់។ យុវជននេះបានវិលទៅកាន់ផ្ទះគ្រួសារវិញ ហើយបានធ្វើតាមការមើលខុសត្រូវនិងលក្ខខណ្ឌធានាឲ្យនៅក្រៅឃុំដ៏តឹងរ៉ឹង។*

*នៅក្នុងពេលស្ថិតនៅក្នុងកម្មវិធីនេះ យុវជននេះបានចុះឈ្មោះរៀននៅ TAFE ក្នុងតំបន់ ហើយបានទទួលឌីប្លូម៉ា ខាងផ្នែកបច្ចេកវិជ្ជាពត៌មាន។*

*នៅពេលដែល Max កំពុងបង្ហាញការរីកចំរើន គេបានបន្ធូរលក្ខខណ្ឌធានាឲ្យនៅក្រៅឃុំរបស់យុវជននេះ ហើយបានបន្ថយចំនួនការបង្ហាញខ្លួនដើម្បីរាយការណ៍។ យុវជននេះមានការអនុញ្ញាតឲ្យធ្វើដំណើរ ដោយគ្មានអ្នកអមដំណើរនៅតាមរថភ្លើង ហើយពេលម៉ោងហាមប្រាមមិនឲ្យធ្វើដំណើររបស់យុវជននេះបានត្រូវដកចេញ។*

*ក្រោយពេលប្រាំមួយខែមក Max កំណត់បញ្ចប់កម្មវិធី YDC របស់ខ្លួន ប៉ុន្តែបានសំរេចបន្ថែមពេលបីខែទៀតសំរាប់កម្មវិធីនេះ ដើម្បីឲ្យគេអាចបំពេញសព្វគ្រប់នូវវិញ្ញាបនបត្របច្ចេកវិជ្ជាពត៌មានដំណាក់កាលទីពីររបស់ខ្លួន មុនពេលគេអាចឡើងតុលាការដើម្បីទទួលការវិនិច្ឆ័យទោស។*

*ចាប់តាំងពីចូលទៅក្នុងកម្មវិធី YDC មក Max មិនបានប្រព្រឹត្តល្មើសសាជាថ្មី ឬមានរបាយការណ៍ ឬ ការសង្ស័យអំពីឧប្បត្តិហេតុណាមួយនៃការប្រើគ្រឿងញៀនឡើយ។*

* នៅក្រោមការផ្តួចផ្តើមបង្វែរចេញពីគ្រឿងញៀនខុសច្បាប់ (Illicit Drug Diversion Initiative) របស់ក្រុមប្រឹក្សានៃបណ្តារដ្ឋាភិបាលអូស្ត្រាលី រដ្ឋាភិបាលសហព័ន្ធកំពុងរួមចំណែកនៅក្នុងការឧបត្ថម្ភប្រាក់ សំរាប់ការផ្តួចផ្តើមបង្វែរចេញនេះ។

*Produced by the Community Drug Information Strategy, NSW Premier's Department.*